អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន
## លោកស្រី MARIE GUIRAU ត្រូវបានតែងតាំង
## ជាសហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រី Marie Guiraud (ជនជាតិបារាំង) ត្រូវបានតែងតាំងជាសហមេធាវីនាំមុខអន្តរជាតិថ្មីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៤ តទៅ។

លោកស្រី Marie Guiraud មានបទពិសោធន៍ រយៈពេល ១៥ ឆ្នាំក្នុងវិស័យនីតិព្រហ្មទណ្ឌ និងនីតិសិទ្ធិមនុស្ស។ លោកស្រីទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិអន្តរជាតិសាធារណៈ និងសិទ្ធិមនុស្សនៅសាកលវិទ្យាល័យ University College London និងសញ្ញាបត្រនីតិសាស្ត្រកម្រិតក្រោយបរិញ្ញាបត្រមកពីសាកលវិទ្យាល័យម៉ុងពីលីយេ (University of Montpellier) ។ លោកស្រីបានតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ចាប់តាំងពីឆ្នាំ ២០០៨ មកម្ល៉េះព្រមទាំងបានតំណាងឲ្យជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិ នៅចំពោះមុខតុលាការនៃប្រទេសកូតឌីវ័រ និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ នៅប្រទេសបារាំង លោកស្រី Marie Guiraud បានតំណាងចុងចោទ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគ្រប់ជំនាញផ្នែកនីតិព្រហ្មទណ្ឌក្នុងនោះរួមមានបទល្មើសភេរវកម្មនិងឧក្រិដ្ឋកម្មឆ្លងដែន។ មុនពេលប្រកបវិជ្ជាជីវៈបណ្តឹងវិវាទ លោកស្រី Marie Guiraud បានធ្វើជាប្រធាននៃការិយាល័យសកលភាវូបនីយកម្ម និងសិទ្ធិមនុស្ស នៅសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (FIDH)។

លោកស្រី Marie Guiraud មានគុណវុឌ្ឍិ ក្នុងការប្រកបវិជ្ជាជីវៈច្បាប់នៅប្រទេសបារាំង និងនៅព្រះរាជាណាចក្រកម្ពុជា ហើយធ្វើការជាភាសាបារាំង និងអង់គ្លេស។ លោកស្រី Marie Guiraud គឺជាសមាជិកក្រុមសកម្មភាពបណ្តឹងវិវាទនៃ FIDH និងជាសមាជិកសមាគមមេធាវីគ្មានព្រំដែន-បែលហ្ស៊ិក។

លោកស្រី Marie Guiraud នឹងធ្វើការរួមគ្នាជាមួយលោក ពេជ អង្គ សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក អាចចូលរួមក្នុងកិច្ចដំណើរការ

នីតិវិធីរួមគ្នាជាដើមបណ្តឹងរដ្ឋប្បវេណី និងស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវធានាឲ្យមានការចាត់ចែងប្រកបដោយប្រសិទ្ធភាពនូវការតំណាងដល់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងអំឡុងពេលនៃដំណាក់កាលសវនាការ និងដំណាក់កាលបន្តបន្ទាប់ទៀត។ ការទទួលខុសត្រូវចម្បងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមមាន: ការតំណាងផលប្រយោជន៍របស់ក្រុមរួមដើមបណ្តឹងរដ្ឋប្បវេណី ការគាំទ្រទូទៅ ការបង្ហាញជាយុទ្ធសាស្ត្រ និងនៅក្នុងតុលាការផ្ទាល់នូវផលប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណី ដោយសហការយ៉ាងជិតស្និទ្ធជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh